# ស្ថានទូតជប៉ុនប្រចាំព្រះរាជាណាចក្រកម្ពុជា

# សេចក្ដីប្រកាសព័ត៌មាន

ថ្ងៃទី២៤ ខែធ្នូ ឆ្នាំ២០១៤

## ជប៉ុនផ្ដល់១៨៦,៦៥០ ដុល្លារអាមេរិកសម្រាប់លើកកម្ពស់មជ្ឈមណ្ឌលសិក្សាសហគមន៍នៅតាមជនបទក្នុងប្រទេសកម្ពុជា



ក្រោមគ្រោងការណ៍នៃជំនួយឧបត្ថម្ភឥតសំណង សម្រាប់គម្រោងរបស់អង្គការក្រៅរដ្ឋាភិបាលជប៉ុន រដ្ឋាភិបាលជប៉ុនបានផ្ដល់ទឹកប្រាក់សរុបចំនួន១៨៦, ៦៥០ដុល្លាអាមេរិក ដល់អង្គការសន្តិស្ម័គ្រចិត្ត (SVA) ។ កិច្ចសន្យាផ្ដល់ជំនួយ ត្រូវបានចុះហត្ថលេខានៅថ្ងៃនេះដោយឯកឧត្តម គូម៉ាម៉ារ៉ូ យូជិ ឯកអគ្គរាជទូតវិសាមញ្ញ និងពេញសមត្ថភាពរបស់ប្រទេសជប៉ុនប្រចាំព្រះរាជាណាចក្រកម្ពុជា និងលោក តាម៉ារិ គីយ៉ូតាកា នាយកអង្គការSVA ដើម្បីអនុវត្ត "គម្រោងលើកកម្ពស់មជ្ឈមណ្ឌលសិក្សាសហគមន៍នៅតាមជនបទក្នុងប្រទេសកម្ពុជា"។

ក្នុងគម្រោងនេះ អង្គការ SVA នឹងសាងសង់មជ្ឈមណ្ឌលសិក្សាសហគមន៍ចំនួនពីរខ្នង ដែលបំពាក់ទៅដោយគ្រឿងបរិក្ខាក្នុងឃុំគោកបល្ល័ង្គ និងឃុំអូរប្រាសាទ ខេត្តបន្ទាយមានជ័យ។ គម្រោងនេះ នឹងផ្ដល់អត្ថប្រយោជន៍ដល់ប្រជាជនជាង ២២,៥០០នាក់ក្នុងឃុំចំនួនពីរ ដែលអាចបង្រៀនអោយចេះអាន និងសរសេរ ដើម្បីអនុវត្តជំនាញនៃការរស់នៅរបស់ពួកគេបាន។ លើសពីនេះ អង្គការSVA ក៏មានផែនការផ្ដល់កម្មវិធីបង្កើនសមត្ថភាពដល់ក្រុមគ្រប់គ្រងការងារ និងបុគ្គលិករបស់មជ្ឈមណ្ឌលសិក្សាសហគមន៍ សម្រាប់ការធ្វើប្រតិបត្តិការប្រកបដោយប្រសិទ្ធភាព។

កម្មវិធីជំនួយឥតសំណង សម្រាប់គម្រោងរបស់អង្គការក្រៅរដ្ឋាភិបាលជប៉ុន បានចាប់ផ្ដើមនៅប្រទេសកម្ពុជាតាំងពីឆ្នាំ២០០២ ដើម្បីគាំទ្រដល់សកម្មភាពរបស់អង្គការក្រៅរដ្ឋាភិបាលជប៉ុន ក្នុងកិច្ចខិតខំប្រឹងប្រែងដើម្បីជួយដល់ការអភិវឌ្ឍ និងស្ដាបនាប្រទេសកម្ពុជាឡើងវិញនៅតាមកំរិតមូលដ្ឋាន។ ចាប់តាំងពីឆ្នាំ២០០២មក រដ្ឋាភិបាលជប៉ុន បានផ្ដល់ថវិកាជាង២២.៣លានដុល្លាអាមេរិក ដល់គម្រោងចំនួន៨២គម្រោង របស់អង្គការក្រៅរដ្ឋាភិបាលជប៉ុន ដែលផ្ដោតសំខាន់ទៅលើវិស័យអប់រំនៅកម្រិតមូលដ្ឋាន វិស័យសុខាភិបាល វិស័យកសិកម្ម និងសកម្មភាពបោសសំអាតមីន។ គម្រោងនេះគឺជាគម្រោងទី៤តាមរយៈគ្រោងការណ៍នៃជំនួយនេះសម្រាប់ឆ្នាំសារពើពន្ធឆ្នាំ២០១៤របស់ជប៉ុន(មេសា២០១៤ដល់មិនា២០១៥)។

---



---


ស្ថានទូតជប៉ុនប្រចាំព្រះរាជាណាចក្រកម្ពុជា

ទូរសព្ទ៖ ០២៣-២១៧-១៦១ ទូរសារ៖ ០២៣-២១៤-៣៣០

អ៊ីមែល: eco.jpn@.pp.mofa.go.jp

គេហទំព័រ: http://www.kh.emb-japan.go.jp